# បឋមសមជីវីសូត្រ

(ធម៌ធ្វើឲ្យគូស្នេហ៍រស់នៅជាសុខនិងជួបគ្នាគ្រប់ជាតិ)

## សុត្តន្តបិដក អង្គុត្តរនិកាយ

## ចតុក្កនិបាត ទុតិយបណ្ណាសកៈ

## បុញ្ញាភិសន្ទវគ្គទី ១ បឋមសមជីវីសូត្រទី ៥

## បិដកលេខ ៤២ ទំព័រ ១៥០

## ព្រមទាំងអដ្ឋកថា មនោរថបូរណី

# បឋមសមជីវីសូត្រ

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុង្សុមារគិរៈ ក្នុងដែនភគ្គៈ ។ គ្រានោះឯងព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់និវេសន៍ របស់គហបតីឈ្មោះនកុលបិតា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ នកុលបិតាគហបតីនិងនកុលមាតាគហបតី បាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ បានថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនកុលបិតាគហបតី អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំព្រះអង្គ បានប្រសប់គ្នានឹងនកុលមាតាគហបតានី តាំងពីកំឡោះ ក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្តនៃនកុលមាតាគហបតានី សូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង ។ ចំណែកនកុលមាតាគហបតានីក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះដែរថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំម្ចាស់បានប្រសប់គ្នានឹងនកុលបិតាគហបតី តាំងអំពីកំឡោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្តនៃនកុលបិតាគហបតី សូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នា ក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតីនិងគហបតានីទាំងឡាយ បើជន

ទាំងពីរនាក់ប្តីប្រពន្ធ ប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ទើបជួបគ្នា ក្នុងបច្ចុប្បន្ននេះផង ជួបគ្នាក្នុងបរលោកផង ។

ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យពេចន៍នៃស្មូម ជាអ្នកសង្រួម (ក្នុងសីល) អ្នកចិញ្ចឹមជីវិត តាមគន្លងធម៌ ប្រពន្ធនិងប្តីទាំងនោះ ពោលពាក្យផ្អែមល្ហែមរកគ្នានឹងគ្នា រមែងមានសេចក្តីចម្រើនដ៏ច្រើន ទាំងមានការនៅជាសុខកើតឡើងដល់គ្នានឹងគ្នា ពួកសត្រូវរមែងអាក់អន់ចិត្តចំពោះជនទាំងពីរនាក់ ដែលមានសីលស្មើគ្នា ជនទាំងពីរនាក់មានសីលនិងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ បើមានចំណង់ក្នុងកាម ក៏រមែងជាអ្នកត្រេកអររីករាយ ក្នុងទេវលោកបាន ។

# អដ្ឋកថាបឋមសមជីវីសូត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសមជីវីសូត្រទី ៥ ដូចតទៅនេះ ៖

បទថា តេនុបសង្កមិ (ស្តេចចូលទៅ) សួរថា ព្រះមានព្រះភាគ ស្តេចចូលទៅដើម្បីរកអ្វី ? ឆ្លើយថា ដើម្បីទ្រង់អនុគ្រោះ ។ ពិតហើយ ព្រះតថាគតកាលស្តេចទៅកាន់ដែននោះ ស្តេចរមែងទៅដើម្បីទ្រង់សង្គ្រោះអ្នកទាំងពីរប៉ុណ្ណោះ ។ បានឮថា នកុលបិតាធ្លាប់ជាបិតារបស់ព្រះតថាគត ៥០០ ជាតិ ធ្លាប់ជាជីតា ៥០០ ជាតិ និងជា ឪពុកមា ៥០០ ជាតិ ។ សូម្បីនកុលមាតាក៏បានជាមាតារបស់ព្រះតថាគត ៥០០ ជាតិ បានជាជីដូន ៥០០ ជាតិ និងជាម្តាយមីង ៥០០ ជាតិ បុគ្គលទាំងនោះ បាននូវសេចក្តីស្រឡាញ់ដូចជាបុត្រ ចាប់ផ្តើមតាំងពីវេលាដែលខ្លួនឃើញព្រះសាស្តា ទើបចូលទៅរក ហើយសម្រេចជាសោតាបន្នបុគ្គលក្នុងបឋមទស្សនៈ (ការឃើញគ្រាដំបូង) ដូចមេគោឃើញកូនគោហើយជាប់ជំពាក់ក្នុងកូនគោ ក៏ហៅថា ហាឆ្កាត ហាឆ្កាត ដូច្នេះ ។ ក្នុងនិវេសន៍គេបានចាត់ចែងអាសនៈទុកថ្វាយដល់ភិក្ខុសង្ឃ ៥០០ រូប ជាប្រចាំព្រះមានព្រះភាគ ស្តេចទើបចូលទៅរកដើម្បីអនុគ្រោះអ្នកទាំងនោះ ដោយប្រការដូច្នេះ ។ បទថា អតិចរិតា (បានប្រព្រឹត្តក្រៅចិត្ត) បានដល់ ប្រព្រឹត្តក្បត់ចិត្ត ។

បទថា  អភិសម្បរាយញ្ច (និងជាតិខាងមុខ)  បានដល់  និងក្នុងលោកខាងមុខ ។ បទថា  សមសទ្ធា (មានសទ្ធាស្មើគ្នា)  បានដល់  ជាអ្នកស្មើដោយសទ្ធា ។ សូម្បីក្នុងសីលជាដើម ក៏ន័យនេះដូចគ្នា ។

ចប់អដ្ឋកថា បឋមសមជីវីសូត្រ ។

(មនោរថបូរណី អដ្ឋកថា សុត្តន្តបិដក អង្គុត្តរនិកាយ)

## សរុបសេចក្តី

ធម៌ធ្វើអោយគូស្នេហ៍រស់នៅជាមួយគ្នាជាសុខ    និងជួបគ្នាគ្រប់ជាតិមានបួនយ៉ាង គឺ ៖

**១. សមសទ្ធា** មានសទ្ធាស្មើគ្នា ។

**២. សមសីល** មានសីលស្មើគ្នា ។

**៣. សមចាគៈ** មានចាគៈស្មើគ្នា ។

**៤. សមបញ្ញា** មានបញ្ញាស្មើគ្នា ។